ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០៩៣២ ព.ណ.អ.វ.ម

ថ្ងៃចន្ទ ៧ រោច ខែ ពិសាខ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ. អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ដល់ ១៥ ខែឧសភា ឆ្នាំ២០២១ នឹងត្រូវលក់ ៣.៩១០រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៤៦០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៥សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី០១ ដល់ ១៥ ខែឧសភា ឆ្នាំ២០២១** នឹងចុះមក ៣.៧៥០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៣០០ រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) |
|---|---|---|---|
| ១ | **Average MOPS** | **០,៤៥៨៨ ដុល្លារ** | **០,៤៤១៧ ដុល្លារ** |
| ២ | **ពន្ធ៖** | **០,១៨៤៧ ដុល្លារ** | **០,០៧៤២ ដុល្លារ** |
| | ពន្ធគយ | ០,០៦៣៥ ដុល្លារ | ០,០០០០ ដុល្លារ |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | ០,០៤០០ ដុល្លារ |
| | អាករពិសេស | ០,១០១៣ ដុល្លារ | ០,០៣៤២ ដុល្លារ |
| ៣ | **PREMIUM** | **០,២០ ដុល្លារ** | **០,២៣ ដុល្លារ** |
| ៤ | **អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣)** | **០,០៨៤៣ ដុល្លារ** | **០,០៧៤៦ ដុល្លារ** |
| ៥ | **ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ)** | ០,៩២៧៨ ដុល្លារ | ០,៨២០៥ ដុល្លារ |
| ៦ | **ថ្លៃលក់រាយ/លីត្រ (គិតជារៀល)** | ៣.៧៥៦ រៀល | ៣.៣២១ រៀល |
| ៧ | **តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ)** | **០,៩៣ ដុល្លារ** | **០,៨២ ដុល្លារ** |
| ៨ | **តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល)** | **៣.៧៥០ រៀល** | **៣.៣០០ រៀល** |

**សម្គាល់៖ អាត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ ដែលស្មើនឹង៤.០៤៨រៀល/ដុល្លារអាមេរិក**

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ៖ (៨៥៥)-២៣ ៨៦៦ ៤៦៩

Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង Gasoil (USD/Barrel) |
|---|---|---|
| ១៦ មេសា ២០២១ | ៧៣,៨៧ | ៧០,៨៦ |
| ១៩ មេសា ២០២១ | ៧៣,៥៥ | ៧០,៥៥ |
| ២០ មេសា ២០២១ | ៧៤,៧៧ | ៧១,០៨ |
| ២១ មេសា ២០២១ | ៧២,៨១ | ៦៩,២១ |
| ២២ មេសា ២០២១ | ៧១,១៩ | ៦៨,៣៧ |
| ២៣ មេសា ២០២១ | ៧១,៩១ | ៦៩,៣៥ |
| ២៦ មេសា ២០២១ | ៧១,១១ | ៦៩,០៦ |
| ២៧ មេសា ២០២១ | ៧១,៧២ | ៦៩,៩៥ |
| ២៨ មេសា ២០២១ | ៧២,៤៦ | ៧០,១៧ |
| ២៩ មេសា ២០២១ | ៧៤,២០ | ៧១,៦២ |
| ៣០ មេសា ២០២១ | ៧៤,៨១ | ៧២,៣៦ |
| **មធ្យមភាគ ១១ថ្ងៃ** | **៧២,៩៤៥៥** | **៧០,២៣៤៥** |
| **មធ្យមភាគ (ដុល្លារ/លីត្រ)** | **០,៤៥៨៨** | **០,៤៤១៧** |

**ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ខែកុម្ភៈ ដល់ ០១ ខែឧសភា ឆ្នាំ២០២១**




សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការចាំបាច់ ។